# សេចក្តីជូនដំណឹង

## ស្តីពី

# ការបែងចែកភាគលាភ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ លើកទី២២ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២, លិខិតលេខ: ៩៥៨/២២ ន.ម.ក. ចុះថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ របស់និយ័តករមូលបត្រកម្ពុជា ស្តីពីការបែងចែកភាគលាភសម្រាប់ឆ្នាំ២០២១ និងលិខិតលេខ: ធ៧-០២២-១១៣៨ ឆ.ត ចុះថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់ធនាគារជាតិ នៃ កម្ពុជា ធនាគារ អេស៊ីលីដា សម្រេចបែងចែកភាគលាភសម្រាប់ប្រាក់ចំណេញក្នុងការិយបរិច្ឆេទឆ្នាំ២០២១ ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | **: សាច់ប្រាក់** |
| ២. | រយៈពេលនៃភាគលាភ | **: ប្រចាំឆ្នាំ** |
| ៣. | អនុបាតនៃការបែងចែកភាគលាភ | **: ៣៥%** |
| ៤. | ភាគលាភសរុបដែលត្រូវបែងចែក | **: ២៣៧.៦៥០.៧៧៥.៣២៥,៦៧ រៀល** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | **: ៥៤៨,៦៤០៥ រៀល** |
| ៦. | កាលបរិច្ឆេទអិចឌីវីដឺនដ៍ | **: ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២** |
| ៧. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) | **: ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២** |
| ៨. | កាលបរិច្ឆេទទូទាត់ភាគលាភ | **: ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២** |

**<u>បញ្ជាក់</u>៖**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២**។
- ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២** គឺ**នៅតែមានសិទ្ធិ**ទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២២** គឺ**មិនមានសិទ្ធិ**ទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ដល់ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២** នៅរៀងរាល់ថ្ងៃធ្វើការ។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើទំនាក់ទំនងមកធនាគារ អេស៊ីលីដា តាមរយៈអាសយដ្ឋាន និងលេខទូរស័ព្ទ ដូចខាងក្រោម៖

- **អាសយដ្ឋាន:** អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃពុធ ៩កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**